THE SCHOOL DISTRICT OF PHILADELPHIA

ការណែនាំសម្រាប់មាតាបិតា

# ការប្រឡង ACCESS សម្រាប់សិស្សដែលត្រូវរៀនភាសាអង់គ្លេស (ELLs)

## តើការប្រឡង ACCESS គឺជាអ្វី?

ការវាយតម្លៃនៃការប្រាស្រ័យទាក់ទង និងការយល់ដឹងភាសាអង់គ្លេសពីរដ្ឋមួយទៅរដ្ឋមួយទៀត សម្រាប់សិស្សដែលត្រូវរៀនអង់គ្លេស (ACCESS for ELLs™) គឺជាការប្រឡងឲ្យដឹងពីការស្ទាត់ជំនាញភាសាអង់គ្លេសដែលផ្អែកលើស្តង់ដារសម្រាប់សិស្សថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២ ដែលត្រូវបានរៀបចំឡើងដើម្បីស្ទង់សមត្ថភាពស្ទាត់ជំនាញភាសាអង់គ្លេសរបស់សិស្សដែលត្រូវរៀនភាសាអង់គ្លេស។ ជាការវាយតម្លៃផ្នែកទំនាក់ទំនង និងការបង្ហាត់បង្រៀន ជាភាសាអង់គ្លេស ព្រមទាំងទាក់ទងនឹងផ្នែក អង់គ្លេស គណិតវិទ្យា វិទ្យាសាស្ត្រ និងសង្គមវិទ្យា ក្នុងបរិបទភាសាតាមវិស័យបួន ការស្តាប់ ការអាន ការនិយាយ និងការសរសេរ។

## តើសិស្សណាខ្លះដែលត្រូវប្រឡង ACCESS?

សិស្សដែលត្រូវរៀនភាសាអង់គ្លេសទាំងអស់ ក្នុងថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី១២ ត្រូវតម្រូវឱ្យចូលរួមជារៀងរាល់ឆ្នាំក្នុងការវាយតម្លៃសមត្ថភាពស្ទាត់ជំនាញភាសាអង់គ្លេស។

## តើធ្វើដូចម្តេចទើបដឹងថាសិស្សត្រូវការរៀនភាសាអង់គ្លេស?

សិស្សដែលត្រូវរៀនភាសាអង់គ្លេស ត្រូវបានធ្វើឡើងតាមរយៈនៃវិធីការមួយដែលចាប់ផ្តើមដោយឲ្យក្រុមគ្រួសារបំពេញការស្ទង់មើលភាសាដែលនិយាយនៅផ្ទះ។ នៅពេលបំពេញការស្ទង់មើលភាសារួច នឹងមានការធ្វើសម្ភាសន៍ ដើម្បីសម្រេចថាតើសិស្សនេះអាចជាសិស្សដែលត្រូវរៀនភាសាអង់គ្លេសឬអត់។ ប្រសិនបើត្រូវបានសម្រេចថាសិស្សអាចជាសិស្សដែលត្រូវរៀនភាសាអង់គ្លេស បន្ទាប់មកគេនឹងឲ្យធ្វើតេស្តឲ្យដឹងពីការស្ទាត់ជំនាញនៃភាសាអង់គ្លេស។

## តើកូនខ្ញុំប្រឡង ACCESS នៅពេលណា?

សិស្សដែលត្រូវរៀនភាសាអង់គ្លេស ត្រូវប្រឡង ACCESS ជារៀងរាល់ឆ្នាំ។ លោកអ្នកអាចមើល [ប្រតិទិនសម្រាប់ការប្រឡងរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា] ព្រមទាំងប្រតិទិនសាលារបស់កូនលោកអ្នក សម្រាប់កាលបរិច្ឆេទជាក់លាក់នៃពេលប្រឡង ACCESS នៅសាលារបស់ពួកគេ។

## តើគ្រូធ្វើអ្វីជាមួយពិន្ទុនៃការប្រឡង ACCESS របស់កូនខ្ញុំ?

គ្រូប្រើលទ្ធផលនៃការប្រលង ACCESS សម្រាប់គ្រូតពិនិត្យការចេះដឹងរបស់សិស្សឆ្ពោះទៅរកការទទួលបាននូវការស្ទាត់ជំនាញភាសាអង់គ្លេស សម្រាប់ការធ្វើផែនការដោយចេតនាក្នុងការបន្ថែមការគាំទ្រ ដើម្បីគាំទ្រសិស្សឲ្យទទួលបានមុខវិជ្ជាតាមកម្រិតថ្នាក់ សម្រាប់ការសំរេចចិត្តអំពីការវាយឈ្មោះ និងរៀបចំការគាំទ្រទៅតាមវគ្គសិក្សាដែលសមស្រប ឬថ្នាក់រៀន និងដើម្បីសម្រេចការចាត់ថ្នាក់ឡើងវិញពីកម្មវិធីអប់រំ និងការបង្ហាត់បង្រៀនភាសា។

## តើសំណួរប្រភេទណាដែលសួរនៅក្នុងការប្រឡង ACCESS?

សិស្សត្រូវប្រឡងវិស័យភាសាចំនួនបួនផ្នែក៖ **ការអាន ការសរសេរ ការនិយាយ** និង **ការស្តាប់**។ មានរបៀបឆ្លើយ ៣ យ៉ាង៖ ១) ការជ្រើសរើសចម្លើយមួយពីចម្លើយច្រើន (ការស្តាប់ និង ការអាន) ២) ការឆ្លើយដែលត្រូវរៀបរាប់ពន្យល់ផ្ទាល់មាត់ (ការនិយាយ) និង ៣) ការឆ្លើយតាមការសរសេររៀបរាប់ជាលាយលក្ខណ៍អក្សរ (ការសរសេរ)។

## តើពិន្ទុប្រភេទណាដែលត្រូវរាយការណ៍លើការប្រឡង ACCESS?

ការប្រឡង ACCESS ផ្តល់ពិន្ទុបីប្រភេទ៖ ពិន្ទុពីការឆ្លើយត្រូវ (raw scores) ពិន្ទុតាមខ្នាតស្តង់ដារ (scale scores) និង ពិន្ទុកម្រិតស្ទាត់ជំនាញ (proficiency level scores)។ **raw scores** គឺជាចំនួនពិត ឬអ្វីៗដែលសិស្សឆ្លើយត្រូវ។ ពិន្ទុនេះគឺជាចំណុចចាប់ផ្តើម ប៉ុន្តែដោយសារវាមិនគិតពីការលំបាក វាមិនជួយអ្នកអប់រំឱ្យយល់ពីលទ្ធផលរបស់សិស្សបានទេ។ ដោយមូលហេតុនេះ raw scores មិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ពិន្ទុ ACCESS for ELLs ទេ។ **scale scores** គិតដល់ការលំបាក ដូច្នេះអ្នកអប់រំអាចប្រើពិន្ទុទាំងនេះដើម្បីពិនិត្យមើលក្រុមសិស្ស ឬលទ្ធផលរបស់សិស្សបានគ្រប់ពេល។ **Proficiency level scores** ផ្តល់នូវការបកស្រាយនៃពិន្ទុដែលធ្វើត្រូវ។ កម្រិតស្ទាត់ជំនាញនៃភាសាអង់គ្លេសមានប្រាំមួយ៖ ១–ចូលដំបូង ២–ចាប់ផ្តើម ៣–អភិវឌ្ឍន៍ ៤–រីកដុះដាល ៥–ឥតភ្លាប់ និង ៦–ដល់កម្រិត។

## តើការប្រឡង ACCESS កំណត់ម៉ោងដែរឬទេ?

ការប្រឡង ACCESS មិនកំណត់ម៉ោងទេ។ អ្នកបង្កើតវិញ្ញាសារប្រឡងប៉ាន់ស្មានថា ជំពូកសម្រាប់ការអានអាចស៊ីពេលប្រហែល ៦០ នាទី ជំពូកនៃការស្តាប់ស៊ីពេលប្រហែល ៦៥ នាទី ជំពូកនៃការនិយាយស៊ីពេលប្រហែល ៥០ នាទី ហើយជំពូកនៃការសរសេរស៊ីពេលប្រហែល ៩០ នាទី សរុបទៅប្រហែល ២៦៥ នាទី នៃការប្រឡង។ ទោះជាយ៉ាងណាក៏ដោយ គេមិនតម្រូវឱ្យសិស្សបញ្ចប់ការប្រឡងតាមម៉ោងដែលប៉ាន់ស្មានទាំងអស់នោះទេ ហើយគេផ្តល់ពេលវេលាថែមទៀតតាមការចាំបាច់ដើម្បីបញ្ចប់ការប្រឡង។

## តើការប្រឡង ACCESS ប៉ះពាល់ដល់ពិន្ទុរបស់កូនខ្ញុំដែរឬទេ?

ការប្រឡងនេះមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ។ ទោះជាយ៉ាងណាក៏ដោយ ពិន្ទុផ្សំនៃការប្រឡង ACCESS (ក៏ហៅថា «កម្រិតស្ទាត់ជំនាញភាសាអង់គ្លេស/English proficiency levels») - ដែលមានពី ១,០ ដល់ ៦,០ - ឲ្យសម្រេចចិត្តវាយឈ្មោះ ឬចាត់តាំងសិស្សឲ្យត្រូវតាម មុខវិជ្ជា/ថ្នាក់រៀន។

## តើកូនខ្ញុំប្រឡង ACCESS ដោយរបៀបណា?

ការប្រឡង ACCESS អាចធ្វើឡើងតាមការប្រើគ្រឿងអេឡិចត្រូនិច ឬខ្មៅដៃ និងក្រដាស។ ដោយមិនគិតពីវិធីណាមួយដែលកូនរបស់លោកអ្នកប្រឡង សិស្សទាំងអស់ត្រូវតែទៅប្រឡង ACCESS នៅសាលារបស់ពួកគេផ្ទាល់។

## តើខ្ញុំអាចមើលលទ្ធផលនៃការប្រឡង ACCESS នៅទីណា?

ក្មេងដែលប្រឡង ACCESS នឹងទទួលរបាយការណ៍ពិន្ទុរបស់សិស្សម្នាក់ៗតាមការផ្ញើទៅផ្ទះដោយសាលារបស់ពួកគេ។ ដើម្បីជំនួយបន្ថែមក្នុងការយល់ដឹងពីរបាយការណ៍ពិន្ទុរបស់សិស្សម្នាក់ៗរបស់កូនលោកអ្នក លោកអ្នកអាចពិគ្រោះជាមួយគ្រូ EL របស់កូនលោកអ្នក។

## តើខ្ញុំអាចទាក់ទងទៅអ្នកណាបើខ្ញុំមានសំណួរថែមទៀតអំពីការប្រឡង ACCESS?

ប្រសិនបើលោកអ្នកមានសំណួរថែមទៀតអំពីការប្រឡង ACCESS យើងសូមឱ្យលោកអ្នកទាក់ទងទៅសាលារបស់កូនលោកអ្នក។ ព័ត៌មានសម្រាប់ទាក់ទងទៅសាលារបស់កូនលោកអ្នកអាចយកពី វិបសៃផ្ទុកព័ត៌មានសាលា របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមអំពីការប្រឡង ACCESS នៅទីណា?

ការិយាល័យវាយតម្លៃសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖ philasd.org/era/assessment

Pennsylvania Department of Education’s ACCESS homepage